# រដ្ឋមន្ត្រីយុត្តិធម៌បញ្ជាឱ្យដោះស្រាយបណ្ដឹងសុំកែសំបុត្រកំណើតជាង៦ពាន់សំណុំរឿងឱ្យចប់នៅដំណាច់ខែមីនា

លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបញ្ជាឱ្យចៅក្រមនៅតាមសាលាដំបូងទាំងអស់ ត្រូវធ្វើយ៉ាងណាដោះស្រាយលើបណ្ដឹងកែតម្រូវអត្រានុកូលដ្ឋាន ឬហៅសំបុត្រកំណើតរបស់ប្រជាលរដ្ឋជាង៦ពាន់សំណុំរឿង ឱ្យចប់នៅដំណាច់ខែមីនា ឆ្នាំ២០២៤ និងមិនត្រូវពាក់ព័ន្ធនឹងផលប្រយោជន៍ជាដាច់ខាត។ លោករដ្ឋមន្ត្រីបានលើកឡើងយ៉ាងដូច្នេះថា៖ «រឿងអត្រានុកូលដ្ឋាន នៅទូទាំងប្រទេសយើងប្រមូលបានមានជាង៦ពាន់រឿង ដែលស្មើនឹង៩០ភាគរយនៃរឿងក្ដីរដ្ឋប្បវេណី ពេលប្ដឹងហើយត្រូវដោះស្រាយឱ្យលឿន អីឡូវខ្ញុំបានសំណូមពរយ៉ាងយូរបំផុតដំណាច់ខែមីនា ត្រូវដោះស្រាយសំណុំរឿងជាង៦ពាន់រឿងនេះចោល។»
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏បានណែនាំដល់មន្ត្រីយុត្តិធម៌ ត្រូវធ្វើយ៉ាងណាដោះស្រាយឱ្យបានឆាប់រហ័សដោយប្រកាន់យកគោលការណ៍ ត្រឹមត្រូវ ឆាប់រហ័ស និងមិនពាក់ព័ន្ធផលប្រយោជន៍។ នេះបើតាមការបញ្ជាក់របស់លោកក្នុងពេលបើកសិក្ខាសាលាស្ដីពីប្រសិទ្ធភាព នៃកិច្ចការនាំពាក្យព័ត៌មាន និងសាធារណមតិសម្រាប់អ្នកនាំពាក្យ និងមន្ត្រីទទួលបន្ទុកព័ត៌មាន នៃក្រសួងយុត្តិធម៌ និងសាលាជម្រះក្ដី នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤។

ពាក់ព័ន្ធនឹងបញ្ហានេះលោក ហ៊ិន ស៊ាងហាក់ អ្នកសម្របសម្រួលគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មើលឃើញថា កន្លងមកតាមរយៈក្រសួងយុត្តិធម៌បានកែទម្រង់ជាច្រើនពាក់ព័ន្ធទៅនឹងវិស័យយុត្តិធម៌ និងតុលាការ ដែលនេះគឺជាយន្តការមួយធ្វើឱ្យប្រសើរឡើងយ៉ាងឆាប់រហ័សទាក់ទងទៅនឹងការជំរុញសំណុំរឿងអត្រានុកូលដ្ឋាន។

មន្ត្រីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរូបនេះបន្តថា ការធ្វើបែបនេះរបស់ក្រសួងយុត្តិធម៌ គឺជាកិច្ចការសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋដែលនឹងត្រៀមទទួលបានផលប្រយោជន៍ពីវិធានការខាងលើ ព្រោះថានៅពេលកែ ឬដោះស្រាយបញ្ហាសំណុំរឿងអត្រានុកូលដ្ឋានមានរយៈពេលយូរ ពលរដ្ឋខាតបង់ទាំងពេលវេលា និងថវិកា ក្នុងនោះក៏ជាការធានាផ្លូវចិត្តជូនពលរដ្ឋដែលកំពុងរង់ចាំទទួលយុត្តិធម៌ផងដែរ៕